សុន្ទរកថារបស់**ឯកឧត្តម គូរ៉ូតៃ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

១៩ តុលា ២០១២

**សូមគោរព ឯកឧត្តម អ៊ុំ ភូមិរ៉ូ អគ្គនាយករងអង្គការ CMAC!**
**សូមគោរព លោក តានីហ្សាវ៉ា យ៉ាស៊ូយូគិ ប្រធានតំណាងអង្គការ JMAS!**
**សូមគោរព អស់លោក លោកស្រី!**

ជាបឋម ខ្ញុំសូមចូលរួមរំលែកនូវមរណៈទុក្ខដ៏ក្រៀមក្រំជាមួយព្រះញាតិវង្សានុវង្ស រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ចំពោះការយាងចូលព្រះទីវង្គតនៃព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ ព្រះមហាវីរៈក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃនេះជាពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយអង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដើម្បីបង្កើនប្រសិទ្ធភាពបោសសម្អាតសំណល់ជាតិផ្ទុះក្រោយសង្គ្រាម។

ជាមួយនឹងជំនួយឧបត្ថម្ភនេះ អង្គការJMASនឹងអនុវត្តគម្រោងប្រមូល និងដុតបំផ្លាញសំណល់ជាតិផ្ទុះក្រោយសង្គ្រាមក្នុងខេត្តចំនួន៥ដែលរួមមានខេត្តតាកែវ សៀមរាប និងកំពង់ធំដែលជាគម្រោង បន្តពីឆ្នាំមុន និងបន្ថែមខេត្តពីរទៀតគឺខេត្តពោធិ៍សាត់ដែលពុំធ្លាប់មានគម្រោងបោសសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងខេត្តកំពង់ឆ្នាំងដែលជាតំបន់គោលដៅសម្រាប់ការទម្លាក់គ្រាប់បែកក្នុងសម័យសង្គ្រាម។ ហេតុដូចនេះហើយ ការអនុវត្តគម្រោងនៅក្នុងតំបន់ទាំងនេះពិតជាមានសារៈសំខាន់ណាស់។

នៅក្នុងគម្រោងនេះ JMASមិនត្រឹមតែធ្វើការប្រមូលនិងដុតបំផ្លាញសំណល់ជាតិផ្ទុះក្រោយសង្គ្រាម ប៉ុន្តែបន្ថែមពីលើនេះ JMASនឹងធ្វើការផ្ទេរបច្ចេកទេសដល់CMAC ព្រមទាំងធ្វើសកម្មភាពបណ្តុះបណ្តាលប្រជាជនមូលដ្ឋានឲ្យស្គាល់ពីគ្រោះថ្នាក់នៃសំណល់ជាតិផ្ទុះក្រោយសង្គ្រាម។ បទឧទ្ទេស និងការពិនិត្យតាមដាននឹងត្រូវបានធ្វើបន្ថែមលើការអនុវត្តផ្ទាល់នៅទីតាំង ក្នុងការផ្ទេរបច្ចេកទេសដល់CMAC ។ ជាងនេះទៅទៀត JMASនឹងពង្រីកគោលដៅនៃការផ្ទេរបច្ចេកទេស និងបែងចែកជំនាញមិនត្រឹមតែទៅដល់ក្រុមCMACដែលអនុវត្តផ្ទាល់ក្នុងគម្រោងនេះ ប៉ុន្តែទៅដល់ក្រុមCMACដទៃទៀតដែលមិនបានអនុវត្តផ្ទាល់ក្នុងគម្រោងនេះក៏ដូចជាទៅដល់គ្រូបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់CMAC។ យើងរំពឹងថា គម្រោងនេះនឹងបង្កើនសមត្ថភាពក្នុងការអនុវត្ត ព្រមទាំងចំណេះដឹងពីការគ្រប់គ្រងសុវត្ថិភាពរបស់សមាជិកCMACទាំងអស់។

ខ្ញុំបានដឹងថា ជាមួយនឹងសកម្មភាពបង្កើនចំណេះដឹង ប្រជាពលរដ្ឋមូលដ្ឋានក៏នឹងត្រូវបានជ្រើសរើសជាសមាជិកក្រុមកាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះប្រចាំសហគមន៍(CBURR)ដែលជាអ្នករាយការណ៍អំពីពត៌មានទាក់ទងនឹងអាវុធជាតិផ្ទុះ។ ជាងនេះទៅទៀត CBURRនឹងធ្វើសកម្មភាពបណ្តុះបណ្តាលប្រជាជនដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយCMAC។ ខ្ញុំសង្ឃឹមថា អាជ្ញាធរ និងប្រជាពលរដ្ឋនឹងចូលរួមក្នុងការកាត់បន្ថយចំនួនជនរងគ្រោះតាមរយៈការបណ្តុះបណ្តាលរបស់CBURRនិងCMAC ទៅដល់ថ្នាក់ដឹកនាំនៅតាមមូលដ្ឋានដែលមានដូចជាអភិបាលស្រុកនិងលោកគ្រូអ្នកគ្រូអំពីគ្រោះថ្នាក់ និងតើត្រូវធ្វើដូចម្តេចនៅពេលប្រទះឃើញអាវុធជាតិផ្ទុះ។

ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងកាត់បន្ថយសំណល់ជាតិផ្ទុះក្រោយសង្គ្រាម និងគ្រោះថ្នាក់របស់ប្រជាជនមូលដ្ឋានដោយសារការធ្វេសប្រហែសចំពោះសំណល់ជាតិផ្ទុះក្រោយសង្គ្រាមបានយ៉ាងច្រើន។ ជាមួយគ្នានេះផងដែរ ខ្ញុំក៏សង្ឃឹមថា ការផ្ទេរបច្ចេកទេសពីJMASទៅ CMACនឹងធ្វើឲ្យសកម្មភាពបោសសម្អាតមីនកាន់តែមានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ជាងមុន។

វត្តមាននៃគ្រាប់មីន និងអាវុធជាតិផ្ទុះគឺជាឧបសគ្គដ៏ធំក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ យើងមិនអាចមើលរំលងបញ្ហានេះនៅពេលពិចារណាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមកិច្ចក៏ដូចជាវិស័យកសិកម្មផងដែរ។ ដោយយោងទៅតាមការពន្យាពេលនៃសន្ធិសញ្ញាOttawa រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅបោសសម្អាតឲ្យអស់នូវមីនប្រឆាំងមនុស្សឲ្យបានត្រឹមឆ្នាំ២០១៩ និងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជំរុញសកម្មភាពបោសសម្អាតមីន។ រដ្ឋាភិបាលជប៉ុនយើង សូមប្រកាសគាំទ្ររាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចគោលដៅនេះ ហើយគម្រោងដែលចុះហត្ថលេខានាថ្ងៃនេះគឺជាសក្ខីភាពក្នុងការគាំទ្រនេះ។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុន ហើយផ្តល់ប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងផ្តល់ប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅតំបន់គោលដៅ ព្រមទាំងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!